# លក្ខខណ្ឌទូទៅនៃការជាវ
# សំបុត្រចូលទស្សនាភាពយន្ត និងព្រឹត្តិការណ៍វប្បធម៌នានា
# នៅវិទ្យាស្ថានបារាំងនៅកម្ពុជា

## ១. គោលបំណង

លក្ខខណ្ឌទូទៅនៃការជាវសំបុត្រចូលទស្សនាភាពយន្ត និងព្រឹត្តិការណ៍វប្បធម៌ ត្រូវបានអនុវត្តចំពោះប្រតិបត្តិការទិញទាំងអស់ដែលធ្វើឡើងនៅក្នុងវិទ្យាស្ថានបារាំងនៅកម្ពុជា មិនថាតាមរយៈប្រព័ន្ធអនឡាញឬ ការទិញសំបុត្រដោយផ្ទាល់នៅបញ្ជរនោះទេ។

## ២. តម្លៃ

- តម្លៃសំបុត្រត្រូវបានកំណត់ជាប្រាក់ដុល្លារអាមេរិក ដោយគិតរួមបញ្ចូលពន្ធជាស្រេច (TTC)។
- វិទ្យាស្ថានបារាំងរក្សាសិទ្ធិក្នុងការកែប្រែតម្លៃនៅពេលណាក៏បាន ប៉ុន្តែសំបុត្រនឹងត្រូវលក់ដោយផ្អែកលើតម្លៃដែលបានកំណត់ជាធរមាននៅពេលបញ្ជាទិញ។

## ៣. របៀបនៃការបង់ប្រាក់

មធ្យោបាយទូទាត់ដែលអនុញ្ញាតរួមមាន៖

- សម្រាប់ការទិញសំបុត្រអនឡាញតាមរយៈគេហទំព័ររបស់វិទ្យាស្ថានបារាំងនៅកម្ពុជា៖ កាតធនាគារ និងការស្កេន QRកូដ។
- សម្រាប់ការទិញសំបុត្រផ្ទាល់នៅបញ្ជរផ្តល់ព័ត៌មានរបស់វិទ្យាស្ថានបារាំង៖ កាតធនាគារ ស្កេនQR និងសាច់ប្រាក់។

ការបង់ប្រាក់ត្រូវធ្វើឡើងតែម្តង និងទាំងអស់នៅពេលបញ្ជាទិញ មិនថាតាមប្រព័ន្ធអនឡាញ ឬនៅបញ្ជរផ្ទាល់។

## ៤. ដំណើរការនៃការបញ្ជាទិញ

<u>ការបញ្ជាទិញតាមប្រព័ន្ធអនឡាញ៖</u>

- ការទិញសំបុត្រតាមប្រព័ន្ធអនឡាញតម្រូវឲ្យអតិថិជនបង្កើតគណនីផ្ទាល់ខ្លួនមួយ។
- អតិថិជនជ្រើសរើសម៉ោងបញ្ចាំងភាពយន្ត ឬកម្មវិធីវប្បធម៌ណាមួយ ក៏ដូចជាចំនួនកៅអីមុននឹងអនុម័តការបញ្ជាទិញ។

- សំបុត្រអេឡិចត្រូនិច (e-ticket) ត្រូវបានផ្ញើតាមរយៈអ៊ីមែល បន្ទាប់ពីអតិថិជនបានការធ្វើការទូទាត់រួច ។
- **អតិថិជនដែលទិញសំបុត្រតាមប្រព័ន្ធអនឡាញត្រូវទិញយ៉ាងយូរបំផុត ៣០នាទីមុនចាប់ផ្តើមកម្មវិធី ។**

<u>ការទិញសំបុត្រនៅទីតាំងបញ្ជរផ្ទាល់៖</u>

អ្នកដែលទទួលបានការបញ្ចុះតម្លៃ(សូមមើលមាត្រា៨)តម្រូវឲ្យធ្វើការទិញសំបុត្រដោយផ្ទាល់នៅកន្លែងផ្តល់ព័ត៌មានរបស់វិទ្យាស្ថាន និងតម្រូវឲ្យបង្ហាញឯកសារបញ្ជាក់ដែលចាំបាច់ដើម្បីទទួលបានអត្រានេះ។

អតិថិជនអាចទិញសំបុត្រផ្ទាល់នៅបញ្ជរផ្តល់ព័ត៌មានក្នុងចន្លោះពេល**៣ម៉ោងមុនការបញ្ចាំងភាពយន្ត ឬកម្មវិធីវប្បធម៌នានា និង យ៉ាងយូរ១៥នាទីបន្ទាប់ពីភាពយន្តត្រូវបានចាក់បញ្ចាំង ឬកម្មវិធីវប្បធម៌បានចាប់ផ្តើម** ។ ក្រោយពេលកំណត់នេះ ការទិញសំបុត្រនឹងមិនត្រូវបានអនុញ្ញាតឡើយ។

- អតិថិជនត្រូវបង្ហាញខ្លួននៅទីតាំងបញ្ជរ ដើម្បីទិញសំបុត្រមួយ ឬច្រើន។
- អតិថិជនជ្រើសរើសភាពយន្ត ឬកម្មវិធីវប្បធម៌ណាមួយដែលខ្លួនចង់ទស្សនា ដែលមានដាក់បង្ហាញលើផ្ទាំងខិត្តប័ណ្ណ។
- ភ្នាក់ងារលក់សំបុត្រ នឹងផ្តល់ជូនតម្លៃអាស្រ័យលើស្ថានភាពរបស់អតិថិជន (សិស្ស សមាជិកបណ្ណាល័យ -ល- )។
- បន្ទាប់ពីជ្រើសរើសតម្លៃសំបុត្រ និងចំនួនសំបុត្ររួច អតិថិជនធ្វើការទូទាត់តាមវិធីណាមួយដែលបានផ្តល់ជូន (សាច់ប្រាក់ កាតធនាគារ ស្កេនQRកូដ)។
- នៅពេលដែលការទូទាត់ត្រូវបានអនុម័ត សំបុត្រនឹងផ្តល់ជូនអតិថិជនជាទម្រង់ក្រដាស ឬអេឡិចត្រូនិក ឬជាត្រាសម្គាល់។

## ៥. ការចូលទៅទស្សនាក្នុងរោងបញ្ចាំងភាពយន្ត ឬព្រឹត្តិការណ៍វប្បធម៌

- អតិថិជនត្រូវបង្ហាញសំបុត្រដែលបានទិញរួច (ក្រដាស ឬអេឡិចត្រូនិក) ឬ ត្រាសម្គាល់ នៅច្រកចូលរោងកុន ឬទីតាំងត្រួតពិនិត្យសំបុត្រចូលទស្សនាព្រឹត្តិការណ៍វប្បធម៌។
- សំបុត្រមានសុពលភាពសម្រាប់តែការបញ្ចាំងភាពយន្ត ឬព្រឹត្តិការណ៍វប្បធម៌នៅថ្ងៃ និងពេលវេលាដែលបានបញ្ជាក់នៅលើសំបុត្រតែប៉ុណ្ណោះ។
- វិទ្យាស្ថានបារាំងរក្សាសិទ្ធិក្នុងការបដិសេធចំពោះបុគ្គលណាដែលមិនបំពេញលក្ខខណ្ឌអាយុអប្បបរមាសម្រាប់ការបញ្ចាំងភាពយន្ត ឬព្រឹត្តិការណ៍មួយចំនួន (ឧទាហរណ៍ ភាពយន្តហាមឃាត់សម្រាប់កុមារអាយុក្រោម ១២ ឆ្នាំ)។

## ៦. ការផ្លាស់ប្តូរ និងការសងប្រាក់វិញ

- សំបុត្រមិនអាចប្តូរ ឬដកវិញបានទេ លើកលែងតែក្នុងករណីមានការលុបចោលការបញ្ចាំងភាពយន្ត ឬព្រឹត្តិការណ៍វប្បធម៌ដោយវិទ្យាស្ថានបារាំង។
- ក្នុងករណីមានបញ្ហាបច្ចេកទេស ឬការលុបចោល អតិថិជននឹងត្រូវបានជូនដំណឹងតាមសារអេឡិចត្រូនិច ឬតាមរយៈបណ្តាញសង្គមរបស់វិទ្យាស្ថានបារាំង។ ការសងប្រាក់វិញអាចត្រូវបានផ្តល់ជូនជាទម្រង់កក់ទុក ឬឥណទាន។

## ៧. ការលុបចោល ឬការកែប្រែការបញ្ចាំងភាពយន្ត ឬព្រឹត្តិការណ៍វប្បធម៌

- វិទ្យាស្ថានបារាំងរក្សាសិទ្ធិក្នុងការកែប្រែ ឬលុបចោលការបញ្ចាំងភាពយន្ត ឬព្រឹត្តិការណ៍វប្បធម៌ក្នុងករណីមានឧបទ្ទវហេតុ ឬប្រធានសក្តិ (ការបែកបាក់បច្ចេកទេស លក្ខខណ្ឌអាកាសធាតុ-ល-)។
- ក្នុងករណីមានការលុបចោលកម្មវិធី អតិថិជននឹងត្រូវបានជូនដំណឹងឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន អំពីដំណោះស្រាយនៃការបង្វិលសងប្រាក់វិញ ឬពីការជំនួសដោយកម្មវិធីផ្សេង។

## ៨. ការបញ្ចុះតម្លៃ និងតម្លៃជាក់លាក់សម្រាប់តែការបញ្ចាំងភាពយន្ត

- ការបញ្ចុះតម្លៃត្រូវបានផ្តល់ជូនអតិថិជនដែលបំពេញតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖
  - សិស្សនិស្សិតដែលបានចុះឈ្មោះរៀននៅមជ្ឈមណ្ឌលភាសានៃវិទ្យាស្ថានបារាំងនៅកម្ពុជា (ដែលមានសុពលភាព)៖ ចូលទស្សនាភាពយន្តដោយឥតគិតថ្លៃសម្រាប់ការបញ្ចាំងថ្ងៃធម្មតា និង តម្លៃ ២ ដុល្លារសម្រាប់ការចាក់បញ្ចាំងក្នុងព្រឹត្តិការណ៍។
  - សមាជិកនៃបណ្ណាល័យពហុឯកសាររបស់វិទ្យាស្ថានដែលមានប័ណ្ណសមាជិក៖ ១ ដុល្លារសម្រាប់ការបញ្ចាំងថ្ងៃធម្មតា និង ២ដុល្លារសម្រាប់ការបញ្ចាំងភាពយន្តក្នុងព្រឹត្តិការណ៍។
- សាមីខ្លួនតម្រូវឲ្យបង្ហាញឯកសារបញ្ជាក់នៅទីតាំងបញ្ជរទិញសបុត្រ។

## ៩. ការការពារទិន្នន័យផ្ទាល់ខ្លួន

- ព័ត៌មានពាក់ព័ន្ធនឹងអតិថិជនដែលប្រមូលបានក្នុងអំឡុងពេលទិញសំបុត្រគឺមានភាពចាំបាច់សម្រាប់ការគ្រប់គ្រងប្រតិបត្តិការ និងដើម្បីគោរពតាមកាតព្វកិច្ចផ្លូវច្បាប់។

- យោងតាមច្បាប់ព័ត៌មានវិទ្យា និងសិទ្ធិសេរីភាពក្នុងការការពារទិន្នន័យ អតិថិជនមានសិទ្ធិចូលប្រើ កែតម្រូវ និងលុបទិន្នន័យផ្ទាល់ខ្លួនបាន ។

## ១០. ទំនួលខុសត្រូវ

- វិទ្យាស្ថានបារាំងមិនទទួលខុសត្រូវក្នុងករណីបាត់បង់ អំពើចោរកម្មក្នុងបរិវេណរបស់វិទ្យាស្ថាន ឬការប្រើប្រាស់សំបុត្រដោយប្រាសចាកពីគោលបំណង។
- វិទ្យាស្ថានមិនទទួលខុសត្រូវចំពោះការខូចខាតដោយប្រយោលដែលបណ្តាលមកពីការប្រើប្រាស់សេវាកម្មលក់សំបុត្រអនឡាញ។

## ១១. សិទ្ធិចូលទស្សនា និងសន្តិសុខសុវត្ថិភាព

អតិថិជនត្រូវគោរពតាមបទបញ្ជាសន្តិសុខជាធរមានរបស់វិទ្យាស្ថាន។ ការបង្កឲ្យមានបាតុភាព ឬការមិនគោរពតាមបទបញ្ជាអាចនាំឲ្យមានមានការបណ្តេញចេញពីរោងកុន ឬកម្មវិធីព្រឹត្តិការណ៍ដោយមិនមានការសងប្រាក់វិញឡើយ។

## ១២. បណ្តឹង

ចំពោះការតវ៉ាណាមួយទាក់ទងនឹងការទិញ ឬប្រើប្រាស់សំបុត្រ អតិថិជនត្រូវបានអញ្ជើញឱ្យទាក់ទងទៅវិទ្យាស្ថានបារាំងនៅកម្ពុជាក្នុងរយៈពេល ៧ថ្ងៃបន្ទាប់ពីព្រឹត្តិការណ៍តាមរយៈអ៊ីមែលខាងក្រោម៖

- info@ifcambodge.com

## ១៣. វិវាទ

ក្នុងករណីមានវិវាទ ត្រូវចូលរួមសហការដោះស្រាយដោយសន្តិវិធី។ ក្នុងករណីមិនសះ វិវាទនឹងស្ថិតក្រោមយុត្តាធិការផ្តាច់មុខរបស់តុលាការរាជធានីភ្នំពេញ។

## ១៤. ដែនអនុវត្តច្បាប់

- លក្ខខណ្ឌទូទៅទាំងអស់ត្រូវបានកំណត់ដោយច្បាប់នៃប្រទេសកម្ពុជា។

**ឈ្មោះអ្នកប្រើប្រាស់/អាណាព្យាបាលស្របច្បាប់ និងហត្ថលេខា៖**

-----------------------------------------------------------------------------